# កិច្ចសំភាសន៍អ៊ុំស្រីសំរិទ្ធី សុខា

ក អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខ អ្នកត្រូវគេសំភាសន៍ឈ្មោះសំរិទ្ធី សុខា

កៈ ជាដំបូងនាងខ្ញុំសុំជំរាបសួរអ៊ុំស្រី!

ខៈ ចាស!

កៈ ចាសអ៊ុំថ្ងៃនេះដែរខ្ញុំមានឧកាសដើម្បីសំភាសន៍អ៊ុំ ហើយខ្ញុំសុំណែនាំឈ្មោះរបស់ខ្ញុំៗឈ្មោះហេង សុជីវីហើយខ្ញុំស្ម័គ្រចិត្តខាងគំរោងសាលា BYU ហាវ៉ៃនៅសហរដ្ឋអាមេរិច(សំលេងរំខាន)និងសំលេងក្មេងយំ) ហើយគំរោងសាលាគេចង់អោយសំភាសន៍ប្រជាជនកម្ពុជាដែលគាតមានប្រវត្តិហើយនឹងគាត់បានធ្លាប់ឆ្លងកាត់ជីវីតច្រើន........

គៈ អត់ចេះស្តាប់សោះ (សំលេងស្រែក)!

កៈចឹងខ្ញុំមានឪកាសបានសំភាសន៍ថ្ងៃនឹង.......

គៈ អាញ់ដេរម៉ែផ្អើលពេញនឹងផលូវហើយ (សំលេងស្រែក)!

កៈ ចឹងអ៊ុំអាចចែករំលែកប្រវត្តិនឹងបទពិសោធន៍របស់អ៊ុំនឹងអោយខាងសាលាគេបានផុសនៅក្នុងវេបសាយដែរឬទេអ៊ុំ?

ខៈ អឺម! កំសត់ណាស់ខ្ញុំ ក្រណាស់គ្មានអ្នកណាក្រប្រហែលខ្ញុំ!

កៈ ចាសអ៊ុំ ជាដំបូងខ្ញុំសុំឈ្មោះរបស់អ៊ុំៗឈ្មោះអីដែរ?

ខៈ ខ្ញុំឈ្មោះសំរិទ្ធិ សុខា!

កៈ ចាសអ៊ុំហើយឈ្មោះនឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណរបស់អ៊ុំដែរឬទេ?

ខៈ ត្រូវ!

កៈ ហើយអី!! អ៊ុំមានអាយុប៉ុន្មានឆ្នាំហើយឆ្នាំនឹង?

ខៈ ៥៩!

កៈ ៥៩ អ៊ុំចាំថ្ងៃខែឆ្នាំកំណើតរបស់អ៊ុំដែរឬទេ? (សំលេងក្មេង)!

ខៈ អត់ចាំទេកូន ចាំបានតែថាឆ្នាំឆ្លូវទាល់តែយកអត្តសញ្ញាណប័ណ្ណបានដឹង!

គៈ ហើយនឹងល្បែងលេងហើយនឹង?

ឃៈ (សំលេងក្មេងយំ)!

កៈ ចាសហើយទៅឆ្នាំទាក់ទងជាមួយនឹងឆ្នាំខ្មែរយើងនឹងច័ន្ទគតិ សុរិយគតិអ៊ុំចាំដែរឬទេ?

គៈ ក្បាលមួយកៅអីឥលូវស្ងាត់មើលៗគេសំភាសន៍ហ៎ (សំលេងក្មេងយំ)!

ខៈ ច័ន្ទគតិខ្មែរយើងក្មួយវេទនាណាស់ មិនចង់ហ៊ាននិយាយ
អ៊ុំមានកូនហើយអ៊ុំវេទនាអ៊ុំជួលគាត់ផ្ទះគេនៅបានអ្នកជិតខាងគេជួយគេជួយតិចម្នាក់!

កៈ ចាសអ៊ុំនឹងហើយ
ឥលូវខ្ញុំសុំសួរអ៊ុំតាមលំដាប់លំដោយបន្ទាប់មកចាំអ៊ុំឆ្លើយហើយចាំខ្ញុំសួរអ៊ុំជាបន្ទាប់មកទៀតចឹងណាអ៊ុំ?

ខៈ ចាស!

កៈ ចាសអ៊ុំជាដំបូងខ្ញុំចង់សួរអ៊ុំថាអ៊ុំមានមុខរបរជាអ្វីដែរអ៊ុំ?

ខៈ អត់មានធ្វើអីផងកូន!

កៈ នៅផ្ទះអ៊ុំណ៎ ជាស្ត្រីមេផ្ទះ?

ខៈ ចាស ជាស្ត្រីមេផ្ទះ!

កៈ ចាសហើយអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខៈ ស្រុកកំណើតខ្ញុំនៅស្អាងប៉ុន្តែអ៊ុំនៅនេះតាំងពីក្មេងដឹងក្តីមកម្លេះ!

កៈ ចាស ហើយអ៊ុំមានក្រុមគ្រួសារប៉ុន្មាននាក់ដែរ? មានន័យថាកូនរបស់អ៊ុំណា?

ខៈ កូនរបស់ខ្ញុំ១២នាក់ នៅសល់តែ៨ទេ!

កៈ ម៉េចចឹងអ៊ុំ?

ខ៖ ស្លាប់អស់ហើយ
ស្លាប់ទាំងអស់នៅ៩តែទើបស្លាប់ថ្ងៃមុនមួយទើបធ្វើបុណ្យ៧ថ្ងៃហើយនឹងទៀតសល់៨!

ក៖ អឺចាស គាត់ស្លាប់ដោយសារមូលហេតុអីដែរអ៊ុំ?

ខ៖ មូលហេតុគ្រោះថ្នាក់ចរាចរណ៍!

ក៖ ចាសសោកស្តាយមែនទែន កូនប្រុសឬក៏កូនស្រី?

ខ៖ កូនប្រុសទាំងប្តីទាំងប្រពន្ធនឹងគេមានប្តីមានប្រពន្ធរួចហើយ!

ក៖ អឹម ហើយគាត់ស្លាប់នឹងគាត់ស្រវឹងឬមួយគាត់ឌុបដើរ.......

ខ៖ គាត់ឌុបជំពូ គាត់យកជំពូមកលក់តែម៉ោង៣ភ្លឺ គេថាវាបុកឆ្កែ!

ក៖ ចាស!

ខ៖ មានចាប់អីគេបាន (ចាប់អ្នកបុកមិនបាន) គេជួយម្នាក់តិចៗមិញនឹងណា
មានអីគ្រាន់តែថ្លៃរោងគេរុះហើយមិញ៩០រៀលណារោងមិញ(៩០$)
៩០រៀលពីរប្រឡោះសោះនឹង៩០រៀលរោងមិញនឹងខ្វះតែ១០រៀល(១០ដុល្លារ) ១០០
សាហាវកាលមុនតែ៧០រៀល(៧០ដុល្លារ)ទេ ខ្ញុំមួយឆ្នាំមួយ ឆ្នាំមុនស្លាប់ម៉ែក្មេកឥលូវស្លាប់កូន!

ក៖ ចាសសុំទោសអ៊ុំដែរលឺចឹងណាអ៊ុំ!

ខ៖ ចាស!

ក៖ អឺចឹងអ៊ុំពិបាកចិត្តខ្លាំងឥលូវកំពុងនៅកាន់ទុក្ខនៅឡើយ!
ចាសហើយអ៊ុំកាលពីមុនអ៊ុំមានឪពុកម្តាយគាត់នៅស្រុកណាដែរ?

ខ៖ នៅកំណើតនៅស្អាងគាត់ស្លាប់ចោលអស់ហើយនៅជំនាន់ពលពត(សំលេងរំខាន)
ខ្ញុំនៅរាល់ថ្ងៃចិញ្ចឹមកូនដោយសារជួលផ្ទះប្តីមានប្រពន្ធចុង!

គ៖ អើត្រូវហើយអាតុលាវាមានដឹងខ្យល់អីវា (សំលេងរំខាន)!

ក៖ ចឹងហើយចុះស្វាមីរបស់អ៊ុំឈ្មោះអីដែរ?

ខ៖ ខ្ញុំឈ្មោះសំរិទ្ធិ សុខា ប្តីខ្ញុំឈ្មោះដុល សុរិន្ទ!

ក៖ ចាស ហើយអ៊ុំមានកូនប៉ុន្មានអ្នកដែរ?

ខ៖ កូនប្រាំបួន!

ក៖ កូនប្រាំបួនតែស្លាប់អស់ពីរន៍អ៊ុំ?

ខ៖ ចាស!

ក៖ អ៊ុំចាំឈ្មោះកូននីមួយៗរបស់កូនអ៊ុំដែរទេ?

ខ៖ ចាំ!

ក៖ គាត់ឈ្មោះអីដែរអ៊ុំ?

ខ៖ ដុល កក្កដា ដុល លីម៉ង(ស្លាប់) នឹងដុល លីម៉ងនឹង! នែ!! អ៊ុំសុទ្ធា អ៊ុំសុធី!

គ៖ អារិតឃើញស្បែកជើងនៅអារិត?

ខ៖ ឈ្មោះវិនណារ៉ូ កូនខ្ញុំច្រើនណាស់ចាំអ៊ឹម!!ឈ្មោះដុល វិនណារ៉ូ ដុល សម្បូរ ដុល សម្បត្តិ ដុល ស្រីកា ប្រាំបី ប្រាំបួននាក់ ទាំងអស់ប្រាំបួននាក់!

ក៖ ចាស ហើយចុះពួកគាត់បានរៀបការអស់ហើយន៍អ៊ុំន៍?

ខ៖ រៀបការអស់ហើយ!

គ៖ នៅសល់តែពីរនាក់ទេ!

ខ៖ ចាសនៅពីរ!

ក៖ គាត់រៀបការនឹងគាត់នៅភ្នំពេញឬគាត់ផ្លាស់ទៅនៅឯស្រុក?

ខ៖ នៅភ្នំពេញ
នៅជាមួយអ៊ុំវិញដដែលទាំងកូនប្រសាទាំងកូនបង្កើតអីនឹងនៅមូលជាមួយខ្ញុំវិញដដែល!

ក៖ អូ!!! ចឹងទាំងប្រាំបីប្រាំបួននាក់នឹងគឺគាត់នៅជាមួយអ៊ុំទាំងអស់នឹងម៉ង?

ខ៖ ចាស!

ក៖ អូ!! ចឹងគ្រួសារធំមែនទែនមានសមាជិកច្រើន (សើច)!

ខ៖ ចាស!

ក៖ ចាសហើយកូនដែលគាត់មិនទាន់មានគ្រួសារគាត់មានអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ដប់បួនដប់ប្រាំឆ្នាំហើយ!

ក៖ ចាស គាត់នៅសិក្សាឬក៏គាត់ឈប់ហើយអ៊ុំ?

ខ៖ ឈប់ហើយ ខ្ញុំអត់មានលុយអោយកូនសិក្សាខ្ញុំក្រ (សំលេងរញ៉េរញ៉ៃ)!

ក៖ អឹម!! គាត់ឈប់ត្រឹមថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ ឈប់ត្រឹមថ្នាក់ទីបួនអីនឹងក៏ឈប់មានបានរៀនអីទៀត!

ក៖ ចាសចុះសព្វថ្ងៃគាត់ធ្វើការនៅណាដែរកូនរបស់អ៊ុំណា?

ខ៖ ធ្វើការសំណង់ទៅពេលណាមានគេមានការងារសំណង់ក៏ទៅធ្វើទៅ
ពេលណាគេហៅកង់បីក៏ទៅជឹកគេទៅ!

គ៖ ជួនកាលគេហៅទៅយកខោអាវបោកទៅស្រីៗធ្វើការបោកគកខោអាវចឹងទៅ!

ខ៖ ជួនកាលគេហៅទៅធ្វើការទៅ
បើគេមិនមានការងារទេនៅជួយបោកគកទៅរស់នៅលើអ៊ុំទាំងអស់!

ក៖ ចឹងសព្វថ្ងៃអ៊ុំធ្វើម៉េចដើម្បីចិញ្ចឹមជីវិតខ្លួនឯង?

ខ៖ ដើររកនេះរកនោះទៅកូនបេះនេះបេះនោះបន្តិចបន្តួចចឹងទៅ!

ក៖ លក់នៅផ្សារក្រមួនយើងនឹងន៍អ៊ុំ?

ខ៖ ចាស!

ក៖ ចឹងអ៊ុំអាចបញ្ជាក់ទីតាំងបានទេសព្វថ្ងៃរស់នៅភូមិឃុំសង្កាត់អា.....

ខ៖ ខ្ញុំនៅភូមិឃុំសង្កាត់ហ្អែស? អឺ......ភូមិឃុំសង្កាត់ឬស្សីកែវ (សំលេងរំខាន) ខណ្ឌឬស្សីកែវ
ក្រុមទី១០ ឃុំបឹងស្រឡាង!

ក៖ ចាសៗ ហេតុអីបានជាអ៊ុំសំរេចចិត្តផ្លាស់ទីលំនៅមកទីនៅទីនេះ? (សំលេងរំខាន)!

ខ៖ អ៊ុំនៅនឹងរហូតនឹង!

ក៖ កាលពីមុនអ៊ុំស្រុកកំណើត....មិនមែនទេ!

ខ៖ ស្រុកកំណើតកើតជានៅនឹងម៉ង ស្រុកកំណើតម៉ែខ្ញុំនៅស្អាងព្រែកតូចនៅហ្វូរ ប៉ុន្តែខ្ញុំកើតជានៅនឹងម៉ង! (សំលេងក្មេង)!

ក៖ ចឹងមានន័យថាម៉ាក់របស់អ៊ុំយកអ៊ុំមកនៅទីនេះ?

ខ៖ ចាសនៅនឹងម៉ងតាំងពីតូចនៅនឹងម៉ង ស្រុកកំណើត!

ក៖ អ៊ុំៗកើតនៅនឹង!

គ៖ ផ្ទះនោះគេលក់ដាក់នៅនឹងមុខហ៎ (សំលេងក្មេង)!

ខ៖ នឹងហើយ!

ក៖ ហើយម៉ាក់របស់អ៊ុំពេលដែលគាត់មុនស្លាប់នឹងគាត់នៅនឹងដែរ?

ខ៖ នៅនឹងដែរ!

ក៖ពេលក្រោយមកដល់ជំនាន់ពលពតគាត់ក៏ជំលៀសទៅ? (សំលេងរំខាន)!

ខ៖ ចាស!

ក៖ ចាស ខ្ញុំសុំសួរបងប្អូនរបស់អ៊ុំវិញមានប៉ុន្មានអ្នកដែរ?

ខ៖ បងប្អូនខ្ញុំប្រាំពីរប្រាំបីនាក់តែស្លាប់អស់ហើយ!

ក៖ អូ!!!

ខ៖ ស្លាប់នៅជំនាន់អាពតអស់ហើយ នៅតែខ្ញុំម្នាក់ឯងគត់!

ក៖ ចាសសោកស្តាយមែនទែនអ៊ុំ ហើយពួកគាត់មានឈ្មោះអីខ្លះអ៊ុំមានចាំទេ?

ខ៖ អួយ មិនទេកូនហើយបងប្អូនខ្ញុំច្រើនណាស់ បងធំបំផុតអេង អៀន មិនចាំទេច្រើនណាស់វិលវល់អស់ហើយ!

ក៖ កាលនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ កាលនឹងខ្ញុំនៅតូចដែរនឹងគិតទៅខ្ញុំហាជាងកូនឯងគិតទៅខ្ញុំនៅតូចដែរនឹង!

ក៖ ដប់ឆ្នាំជាងន៏អ៊ុំ?

ខ៖ យូរហើយសាបសែសិបឆ្នាំហើយ!

កៈ ចាសអ៊ុំ ហើយអ៊ុំកាលនឹងគេជំលៀសអ៊ុំទៅណាដែរអាពត
គេជំលៀសអ៊ុំពីភូមិនេះទៅណាដែរ?

ខៈ ទៅភូមិចំការលើ សង្កាត់ទឹកជោ(ស្តាប់មិនច្បាស់)!

កៈ អឺម គេប្រើអ៊ុំធ្វើអីខ្លះកាលនឹង?

ខៈ កាលនឹងច្រូតស្រូវ រែកដីរែកអីគ្រប់សព្វទាំងអស់
ជំនាន់អាពតដែលអោយយើងនៅទំនេរបានហ្អែស? អត់ដែលបានទេ!

កៈ ចាសខ្ញុំលឺតែគេនិយាយដែរថាពិបាក
ហើយអ៊ុំសំណាងហើយដែលបានរួចផុតពីជំនាន់នឹងន៍អ៊ុំ!
ចុះអ៊ុំអាចចែករំលែកបទពិសោធន៍របស់អ៊ុំកាលនៅជំនាន់ពលពតបានទេ?
ថាកាលនឹងគេប្រើអ៊ុំធ្វើការអីខ្លះហើយអ៊ុំជួបការលំបាកអីគេខ្លះដែរ? (សំលេងរំខានរញ៉េរញ៉ៃ)!

ខៈ អឺម ខ្ញុំពិបាកណាស់ អោយតែឆ្នាំច្រូតខែច្រូតៗ ខែរែកដីរែកដី គ្មានពេលទំនេរទេ
ជំនាន់អាពតវាប្រើយើងធ្វើការទាល់តែកប់ព្រលប់កប់អី(ប្រើធ្វើការទាល់ទេយប់ព្រលប់ទើបអោយឈប់) រែកដីទប់ប្រឡាយទឹក!

កៈ ទប់ប្រឡាយទៅហ៎អ៊ុំ?

ខៈ នឹងហើយទប់ភ្លឺស្រែទប់អីនឹង!

កៈ អ៊ុំពេលនឹងមានឈឺអីទេអ៊ុំកាលជំនាន់ពលពតនឹង?

ខៈ ឈឺ និយាយមិនឈឺម៉េចកូន
បើយើងពីមុនយើងមិនដែលរែកចឹងពេលទៅរែកដីចឹងវាប្រាកដជាឈឺហើយយើងរែកដីរែកអី!

កៈ អ៊ុំឈឺអីដែរកាលនឹងអ៊ុំ?

ខៈ អូ!! រែកដីធ្ងន់ណាស់យើងទៅពីភ្នំពេញទៅយើងមានដីទៅដល់នោះគ្មានដីទេ
(ស្តាប់មិនច្បាស់សំលេងក្មេងស្រែកឡូឡា)!

កៈ អឺមអ៊ុំ! ហើយកាលឈឺនឹងគេយកអ៊ុំទៅពេទ្យទេ?

ខៈ អត់ទេគេអោយយើងផឹកទឹកស្តៅសំបកស្តៅទឹកបីយកទឹកមួយញាក់មួយថ្ងៃពីរដង!
(សំលេងរំខាន)!

កៈ ចាសចឹងមានន័យថាយើងក្តៅៗខ្លាំងពេក ចឹងគេអោយផឹកទឹកក្តៅទៅបាត់ទៅអ៊ុំ?

ខៈ នឹងហើយ!

កៈ ចុះអ៊ុំមានឈឺអីផ្សេងក្រៅពីក្តៅខ្លួននឹងទេ?

ខៈ ឈឺ! ហើមជើងហើមអីដើរខ្ញែកខ្លក់ៗ (ដើរមិនត្រង់) ឥលូវរាល់ថ្ងៃនឹងក៏ឈឺដែរឈឺត្រង់នឹងឡើងជាតិអាស៊ីត(សំលេងរំខានរញ៉េរញ៉ៃ) ដល់ហើមភ្នែកខាងនេះនឹងត្រង់នេះ ដល់ឥលូវយើងមានទុក្ខលំបាកក្នុងគ្រួសារយើងកូនយើងទើបនឹងបានប្រាំពីរថ្ងៃនឹង!

គៈ អេៗនៅកន្លែងណា? (សំលេងកូនក្មេង)!

ឃៈ នៅកន្លែងនោះលក់មួយ ពីរពាន់នឹង(សំលេងកូនក្មេង)!

ឃៈ ណាយកស្បែកជើងចោលនឹង យកស្បែកជើងអោយប្អូនវិញ(សំលេងរំខាន)?

គៈ អូ នៅនោះនឹងគេលក់ម៉ាគំនរហ៍........(សំលេងរំខាន)!

កៈ ចាស ហើយអីកាលពីជំនាន់ពលពតនឹងអ៊ុំបានរបបអាហារយ៉ាងម៉េចដែរអ៊ុំ បបរឬក៏បាយ......

ខៈ អឺម បបរហើយរាំទៀតន៍ បបរនឹងក៏ហ៊ុតទឹកបបរនឹងទៅ!

គៈ នេះខ្ញុំយកអាមួយនេះ (សំលេងក្មេង)!

ឃៈ ធំពេកហើយហី(សំលេងរំខាន)!

កៈ ចាស ចុះអ៊ុំចាំទេកាលនឹងអ៊ុំធ្លាប់ពិសារអីគេខ្លះម្ហូបអីគេខ្លះ ដែលពលពតដួសអោយយើង?

គៈ នេះម៉ាក់យកអាមួយនេះ (សំលេងក្មេងស្រែក)!

ខៈ អឺម! មានម្ហូបអីកូន ស្លសម្លម្ជូរព្រលឹតត្រកួនអំបិល......

គៈ នេះដេវិតពាក់ស្បែកជើងនេះសិនទៅកូន!

ខៈ គេអោយយើងហូបចឹងនឹងមានតែចឹងនឹង!

កៈ ប៉ុន្នឹងហ៎អ៊ុំ?

ខៈ នឹងហើយ!

កះ អឹម! ហើយអ៊ុំមាននៅចាំថាកាលពីនឹងអ៊ុំមានធ្វើខុសអីគេធ្វើបាបអីដែរទេ?

គះ កង់ៗរបស់ពីគេនេះ? (សំលេងរំខាន)!

ឃះ កង់អា......

គះ ហ្អែងជិះមកទុកចឹង?

ងះ យកទៅមីងមួយដបមួយពាន់ប្រាំ! (សំលេងរំខាន)!

គះ អានេះក៏មួយដប់មួយពាន់ប្រាំដែរ! (សំលេងរំខាន)!

ខះ ធ្វើ! យើងយកយើងបេះស្រូវផើមនឹងមកបុកមកអីទៅគេចាប់ចងយើងក៏មាន!

កះ ចាស!

ខះ តែយើងមានទោសតែត្រឹមលួចស្រូវគេស៊ីចឹង បុកជាអង្ករចឹងរែកអំទៅដាំបាយ អង្ករឆៅអីចឹងទៅស៊ីទៅ!

គះ ទិញនៅឯណាៗ (សំលេងរំខាន)?

ឃះ អេ! ជិះកង់មួយមើល (សំលេងក្មេង)!

កះ គេទាន់ចឹងគេវ៉ៃអីដែរទេ?

ងះ ណោះ (សំលេងមនុស្សស្រី)!

ខះ គេមិនវ៉ៃយើងទេ គ្រាន់តែចងយើងចងដូចស្លាបសេកចឹងគំរាមយើង!

ឃះ មីអូនៗ (សំលេងអ្នកផ្សេង)!

កះ អឹម កាលនឹងប៉ុន្មានដងដែរបានគេនាំអ៊ុំទៅនឹង?

ខះ បីដងគេទាន់នឹង មិនថាប៉ុន្មានដងទេជំនាន់អាពតតែឃើញយកទៅភ្លាមម៉ង!

កះ ចឹងហ៎(សើច) អូ!

ខះ មិនបាច់ទុកអោយមានពីរបីដងទេ!

កៈ ចាស ហើយអឺ! កាលនឹងអ៊ុំចាំអីគេខ្លះដែលធ្វើអោយអ៊ុំភ្លេចមិនបានកាលជំនាន់ពលពតនឹង? (សំលេងរំខានពីខាងក្រៅ)!

ខៈ មិនចាំទេកូនវិលវល់អស់ហើយ!

កៈ វិលវល់អ៊ុំន៍! ចឹងអឺ ឥលូវអ៊ុំសព្វថ្ងៃនឹងអ៊ុំមានការរស់នៅនឹងមានជីវភាពអីមធ្យមន៍អ៊ុំ អ៊ុំអាចនឹងចិញ្ចឹមខ្លួនឯងនឹងក្រុមគ្រួសារបាន!

ខៈ នឹងហើយមធ្យម វាមិនហូរហៀរដូចគេទេ!

កៈ ធៀបទៅនឹង......

ខៈ ពិនគ្រាន់តែថាយើងគ្រប់គ្រាន់ពេលណាទៅយើងវាទាល់ខ្វះព្រឹកខ្វះល្ងាចដែរ!

កៈ បើធៀបទៅនឹងកាលជំនាន់មុនអ៊ុំគិតថាជំនាន់មុននឹងជំនាន់នឹងតើអ៊ុំពេញចិត្តជំនាន់ណាមួយដែរ?

ខៈ ជំនាន់ៗគេមុនយើងនៅក្មេងពិបាកដែរ ក្មេងជំនាន់មុនយើងអាងបងៗចិញ្ចឹមម៉ែឪនៅចិញ្ចឹម.....

ឃៈ ម៉ោម៉ាក់ជូតញើសអោយកុំដើរលេងខ្លាំងពេកម៉ែសុំសំពះ! (សំលេងអ្នកផ្សេង)!

ខៈ ដល់ឥលូវយើងចិញ្ចឹមខ្លួនយើងៗមានកូនមានចៅវេទនាដូចកាលម៉ែឪយើងចិញ្ចឹមយើងចឹងដែរណាស់!

កៈ អឺម ចឹងអ៊ុំអាចអឺរៀបរាប់ប្រវត្តិរបស់អ៊ុំថាពេលដែរអ៊ុំដាច់អាពតម៉ោថាតើអ៊ុំមានមុខរបរអីខ្លះដើម្បីចិញ្ចឹមខ្លួនឯងអោយរស់ហើយដល់កូនៗទៀតអ៊ុំអាចចែករំលែកបានទេ?

ខៈ អឺម!! មុខរបរពីនឹងម៉ោ យើងមកពីជំនាន់អាពតយើងការបណ្ដោយការហើយប្ដីយើងចិញ្ចឹមចឹងទៅបានប្ដីចិញ្ចឹមចឹងណាប្ដីខ្ញុំធ្វើការបំរើប្រជាជននឹងធ្វើរដ្ឋបំរើប្រជាជនកាលនឹងបំរើប្រជាជនដូចតែគ្នាទេខ្វះព្រឹកខ្វះល្ងាចដែរនឹងកូន

វាមិនហូរហៀរដូចថាយើងនេះទើបតែតលូវបានវារីក (ពីមុនគាត់ក្រខ្សត់ទើបតែសព្វនេះគាត់មានជីវភាពធូរធារ)!

ក៖ អឹម លោកពូគាត់មានមុខរបរជាអីដែរ?

ខ៖ គាត់ធ្វើការនៅជាចៅសង្កាត់ ធ្វើការនៅសង្កាត់!

ក៖ គាត់ចៅសង្កាត់ហ៎?

ខ៖ ចាស!

ក៖ នៅសង្កាត់ណាដែរ?

ខ៖ សង្កាត់ឬស្សីកែវយើងនេះនឹង!

ក៖ចាសហើយអ៊ុំដល់ពេលចឹង.........

គ៖ Sorry about that! (សំលេងអ្នកផ្សេង)!

ក៖ អ៊ុំគិតមានមោទនភាពចំពោះលោកពូដែលបានជួយធ្វើការងាយរដ្ឋនិងបំរើប្រជាជន!

ខ៖ ចាស!

ក៖ ហើយកាលនឹងអ៊ុំស្រលាញ់លោកពូដោយស្ម័គ្រចិត្តឬក៏ឪពុកម្ដាយបង្ខំដែរ? (សំលេងរំខាន)

ខ៖ ស្ម័គ្រចិត្តគេមកដណ្ដឹងយើងនឹង!

ក៖ ស្រលាញ់គ្នាហ៎អ៊ុំកាលនឹង?

ខ៖ ចាស!

ក៖ ហើយអ៊ុំលោកពូអ្នកស្រុកកំណើតនៅឯណាដែរ?

ខ៖ នៅនេះ.....នៅស្អាងព្រែកតូចដូចគ្នាឯង!

ក៖ នៅអ្នកជិតខាងគ្នាន៍អ៊ុំ?

ខ៖ ចាស!

ក៖ ចាស ចឹងអ៊ុំស្គាល់គ្នាតាំងពីតូចៗ?

ខ៖ ស្គាល់គ្នាត្រឹម៧៩នេះឯង!

ក៖ ដាច់ភ្លាមស្គាល់ភ្លាម(សើច)!

ខ៖ នឹងហើយ!

ក៖ ហើយស្រលាញ់គ្នាម៉ង (សើច)!

ខ៖ (សើច)!

ក៖ ចាសតើអ៊ុំមានកម្រងអនុស្សាវរីយ៍អីល្អៗរវាងអ៊ុំប្រុសនិងអ៊ុំស្រីដែរទេ?

ខ៖ មានណា ជួនកាលមានជួនកាលអត់មានដែរនឹងមានប្ដីប្រពន្ធតែងតែនេះហើយកូនចាននឹងរាវតែងមានរណ្ដំគ្នាចុះទម្រាំប្ដីប្រពន្ធ!

ក៖ ចាស តើអ៊ុំស្រលាញ់លោកពូដោយសារអីដែរអ៊ុំ?

ខ៖ (សើច) គាត់មកស្រលាញ់យើង ហើយបើតាមចិត្តខ្ញុំមិនសូវស្រលាញ់គាត់ទេខ្លាចគេធ្វើបាបយើង! (សំលេងរំខានរញ៉េរញ៉ៃ)!

ក៖ កាលពីមុនអ៊ុំស្រលាញ់លោកពូអឺ.....ដោយសារគាត់ស្រលាញ់អ៊ុំមុនចឹងហ៎?

ខ៖ អឹម!

ក៖ ចឹងស្រលាញ់ម៉ងទៅ ហើយចឹងហើយអ៊ុំជីវិតក្រោយពេលរៀបអាពាពិពាហ៍ហើយនឹងអ៊ុំជួបការលំបាកអីខ្លះទៅ?

ខ៖ ការលំបាកចាប់ពី តាំងពីយើងមានកូនមួយកូនពីរចាប់ពិបាកមករហូតមក (សំលេងរញ៉េរញ៉ៃ) និយាយអោយចំគឺពិបាកម៉ងពីមុនៗយើងធ្វើការនៅហាងសាំងយើង យើងធ្វើការនៅនឹង(សំលេងរញ៉េរញ៉ៃ) ធ្វើការវេទនាណាស់កូនអើយវេទនាពិបាកការពិបាកនឹងគ្មានអ្នកណាទៅចង់ពិបាកទេ បើគេអ្នកមានបានស្រួលមិនពិបាក!(សំលេងកូនក្មេងរំខានរញ៉េរញ៉ៃ)!

គ៖ អត់មូលធឹកទេហ៎? (សំលេងអ្នកផ្សេង)!

ឃ៖ កុំៗ (សំលេងក្មេងយំ)!

គ៖ មិញរបស់អ្នកណាគេៗ (សំលេងអ្នកផ្សេង)!

ក៖ ហើយអ៊ុំពេលដែលអ៊ុំជួប.....

គ៖ លុយរបស់ហ្អែង៥០០រយលុយរបស់អាញ់មួយពាន់ (សំលេងរំខាន)!

ក៖
លោកពូមានគ្រួសារហើយនឹងជីវិតរបស់អ៊ុំបានឆ្លងការលំបាកចុះអ៊ុំបានឆ្លងកាត់ដូចថារឿងណាដែលធ្វើអោយអ៊ុំសប្បាយចិត្តណាស់រឿងដែលសប្បាយចិត្តមានដែរទេអ៊ុំ?(សំលេងរំខាន)!

ខ៖ អឺម ពេលណាសប្បាយៗទៅពេលណាអត់ៗភ្លាមទៅកូនតែគេមិនធ្វើអោយយើង!

គ៖ (សំលេងសើច)!

ក៖ ចាស់ រឿងសប្បាយចិត្តអីខ្លះដែលអ៊ុំបានជួប?

ខ៖ ហ៊ឹម!
ថ្ងៃណាយើងមានស៊ីទៅសប្បាយទៅថ្ងៃណាអត់ស៊ីទៅម៉េចនឹងសប្បាយកូនអានឹងយើងនិយាយអោយចំចឹងម៉ងទៅថ្ងៃណាយើងរកលុយបានទិញម្ហូបទិញអីយើងហូបចឹងសប្បាយទៅថ្ងៃណាអត់ពិបាកចិត្តទៀតទៅ!(សំលេងរំខាន)!

ក៖ ចាសអ៊ុំ
ហើយអឺ.....ទាក់ទងជាមួយនឹងការដែលអ៊ុំឆ្លងកាត់បទពិសោធន៍ជីវិតច្រើនតាំងពីក្មេងរហូតមកឥលូវនេះអ៊ុំគិតថាអ៊ុំនឹងមានគំរោងផែនការយ៉ាងណាទៀតសំរាប់ទៅថ្ងៃអនាគតដើម្បីចិញ្ចឹមខ្លួនឯងចិញ្ចឹមគ្រួសារអ៊ុំមានផែនការអីទៅថ្ងៃអនាគត?

ខ៖ អ៊ឹមកូន និយាយពីរឿងនឹងពិបាកម៉ង (សំលេងរំខាន)
ព្រោះរឿងពិបាកគ្មានរឿងសប្បាយអ៊ុំនិយាយអ៊ុំកំពុងតែកាន់ទុក្ខតាំងពីកូនគ្រោះថ្នាក់ចរាចរណ៍អត់មានស្គាល់ជាតិព្រះម៉េទេ(គាត់ពិសារបាយមិនកើត)!(មានសំលេងរំខានពីខាងក្រៅ)!

ក៖អ៊ុំអាចនិយាយអ្វីបានតែអ្វីដែលអ៊ុំនិយាយទៅថាអ៊ុំកាន់ទុក្ខហើយអ៊ុំពិបាកចិត្តអីគេខ្លះ?
ហើយអ៊ុំចង់ធ្វើម៉េចដើម្បីអោយរំសាយទុក្ខកង្វល់ទាំងអស់នឹងណាស់អ៊ុំអាចនិយាយបាន!(សំលេងឡូឡារំខាន)!

ខ៖
អ៊ឹមកូនអ៊ុំកាត់បន្ថយការពិបាកចិត្តបានអោយតែកូននឹងជួយរកចិញ្ចឹមម៉ែចឹងទៅព្រោះកូននៅលើបន្ទុកខ្ញុំទាំងអស់ មានតែពិបាកចឹង(សំលេងរំខានក្មេងយំនឹងមនុស្សធំឡូឡា)!

ក៖ អឹម! ចឹងអ៊ុំចង់អោយអ្វីដែលអ៊ុំសប្បាយចិត្តនឹងអ៊ុំចង់អោយកូនរបស់អ៊ុំទាំងអស់មានជីវភាពធូរធាររកស៊ីមានបានមានសុភមង្គល!

ខ៖ នឹងហើយចង់ចឹង!

ក៖ អឹម......ហើយដល់ពេលអ្វីដែលអ៊ុំប្រាថ្នាចង់បានសំរាប់ជីវិតខ្លួនឯងអ៊ុំមានអីគេខ្លះដែរ?(សំលេងរញ៉េរញ៉ៃ)!

គ៖ (សើច)!

ឃ៖ កុំសើចគេកំពុងនិយាយពីជីវិតពិតអីណានោះ (សំលេងរំខាន)!

ខ៖ ចង់ចឹងដូចថាជួយអោយតែបានម៉ានេះកូនពិបាកណាស់ (មានសំលេងរំខានស្តាប់មិនច្បាស់) រាល់ថ្ងៃនេះពិបាកណាស់នេះកូនប្រសាហើយនេះ (សំលេងមនុស្សធំឡូឡា)!

គ៖ (សើច)!

ក៖ ហើយអីចឹងពេលដែលអ៊ុំមានគ្រួសារហើយៗសុំបកទៅពីពេលដែលអ៊ុំនៅពីក្មេងវិញកាលនឹងអី .....មានក្តីប្រាថ្នាអីគេដែរដែលអ៊ុំគិតថាពេលដែលអ៊ុំធំឡើងអ៊ុំចង់ធ្វើវាណាស់?(សំលេងសើចពីខាងក្រោមក)!

ខ៖ ចេះតែប្រាថ្នាចង់ធ្វើហើយកូនប៉ុន្តែយើងវាធំឡើងៗដឹងក្តីឡើងដាច់អាពតចូលទៅអាពតបណ្តោយ(ពេលដែលគាត់ធំឡើងគាត់ស្ថិតនៅក្នុងសម័យពលពតនិងផុតជំនាន់ពលពត) ធ្វើអីកើតដាច់អាពតបាត់!

ក៖ ចាស់ចុះកាលនៅក្មេងៗតូចៗវិញនោះអ៊ុំ?

ខ៖ នៅពីសង្គមតូចៗនឹងយើងនៅលេងសប្បាយជាមួយម៉ែឪយើងចេះតែសប្បាយហើយព្រោះយើងមិនទាន់ដឹងក្តីថាចង់ធ្វើអី.......

គ៖ គេសួរថាចិត្តម៉ែឯងប្រាថ្នាចង់ធ្វើអីនឹងណា?

ខ៖
ប្រាថ្នាចង់ធ្វើម៉េចអោយមានដូចគេឯងនឹងណាប្រាថ្នាអោយបានជាឧកញ៉ាចឹងទៅកុំអោយវាពិបាកជួបតែក្រីក្រចឹងណាស់!(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាស់ចឹងហើយកាលនឹងអ៊ុំបានចូលរៀនដែរឬទេកាលនឹង?

ខ៖ អត់ទេ ម៉ែឪក្រ!

គ៖ (សំលេងរំខាន)!

ក៖ មិនបានចូលសិក្សាទេន៍អ៊ុំ?

ខ៖ អត់ទេ!

ក៖ ចាស់ហើយអ៊ុំចង់ចូលរៀនទេកាលនឹង?

ខ៖ចង់ដែរតែម៉ែឪគាត់នេះទាល់តែបានកូនគាត់ធំៗទៅហើយដល់តែកូនធំមានប្ដីហើយទៅរៀនមិនកើត!

ក៖ ចាស់ចុះសព្វថ្ងៃអ៊ុំចេះសរសេរចេះអានដែរឬទេ?

ខ៖ អត់សោះ អានមិនកើតទេកូនមិនចេះទេ!

ក៖ ចុះចំណែកភាសាវិញអ៊ុំបានរៀនទេ អត់ដែរ?

ខ៖ អត់!

ក៖ អ៊ុំមានបងប្អូននៅក្រៅប្រទេសដែរទេអ៊ុំ?

ខ៖ អត់ទេក្មួយ (សំលេងរំខាន)!

ក៖ អត់មានទេន៍អ៊ុំ?

ខ៖ អត់ (សំលេងរំខាន)!

ក៖ ចាស់ ហើយកាលពីក្មេងនឹងកាលនឹងអ៊ុំចូលចិត្តលេងល្បែងអីជាងគេដែរអ៊ុំ?

គ៖ (សំលេងរំខាន)!

ខ៖ ចូលចិត្តលេងល្បែងប្រជាប្រិយចូលឆ្នាំចូលអី(ពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ)!(មានសំលេងរំខានពីខានក្រៅ)!

ក៖ មានដូចជាអីខ្លះតាមតែអ៊ុំចងចាំណាស់?

ខ៖ល្បែងប្រជាប្រិយពេលចូលឆ្នាំនឹងមានអីទេមានតែល្បែងចោលឈូងទាញព្រ័តហើយរាំលេងនឹងទៅ!

ក៖ ហើយអ៊ុំទៅលេងនៅណាខ្លះដែរ?

ខ៖ នេះនៅនឹងផ្ទះយើងនឹង!

ក៖ នៅនឹងនេះម៉ង?

ខ៖ ចាស់ (សំលេងរំខាន)!

ក៖ ហើយអឺ...ពេលនឹងអ៊ុំគិតថាអ៊ុំចូលចិត្តលេងល្បែងអីខ្លាំងជាងគេក្នុងចំណោមល្បែងជាច្រើនចឹងអ៊ុំចូលលេងល្បែងអីដែរ?

ខ៖ ជំនាន់កូនរបស់និយាយទៅនាំកូនរបស់អ៊ុំលេងចឹងទៅកាលនឹងជំនាន់នឹងខ្លាចប្រុសៗណាស់មិនដូចឥលូវស្រីៗមិនដឹងមុខទេ....ចុម(សំលេងធ្លាក់របស់និងសំលេងសើច) យើងនាំកូនលេងចឹងទៅយើងលេងចឹងយើងភ័យដែរណាស្មើនេះអីនឹងយើងនាំគ្នាចូលផ្ទះទៅម៉ោង៥អីនឹងណាជំនាន់នឹងខ្លាចប្រុសៗមិនដូចឥលូវទេ!

ក៖ ចាសហើយអឺ....អ៊ុំសំរាប់ក្រៅពីល្បែងប្រជាប្រិយដែលអ៊ុំចូលចិត្តលេងនឹងអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរឬទេ?

គ៖ បងធ្វើព្រះវេស្សន្តសុំប្រាថ្នាកើតជាតិណាៗកុំអោយបងវេទនាដូចជាតិនឹងទៀតបងហើយកើតជាតិណាៗកុំអោយបងវេទនាចឹងទៀតសារក្រោយ.....

ខ៖ អូ! ចំរៀងកាលពីសង្គមនឹងមិនដូចឥលូវណា!

ក៖ ចាស់អ៊ុំហើយកាលពីសង្គមនឹងអ៊ុំចូលចិត្តស្តាប់បទចំរៀងអីដែរ?

គ៖ ស៊ីដាមាសបងអើយ(សំលេងមនុស្សប្រុសគាត់ស្រែរឹង)!

ឃ៖ ប៉ាៗ (សំលេងកូនក្មេង)!

ក៖ ចាស់ចឹងខ្ញុំសុំសំភាសន៏អ៊ុំបន្តទៀត ទាក់ទងជាមួយនឹងបទចំរៀងដែលអ៊ុំចូលចិត្តកាលពីជំនាន់ដើមនឹងណាស់....

គ៖ ស្តាយភូមិកំណើត!

ខ៖ មានចំរៀង......

គ៖ ស្តាយភូមិកំណើតម៉ែឯងច្រៀងជាមួយខ្ញុំហ៎!(សំលេងសើច)!

ខ៖ ចំរៀងពីសង្គមនឹងមានតែស៊ិនស៊ីមុតអីនឹងចំរៀងមិនដូចឥលូវទេកូន......

គ៖ ស្តាយភូមិកំណើតស្តាយអនុស្សាវ......

ឃ៖ ម៉ែថាអោយឥលូវហើយនោះ (សើច)!

ក៖ ចឹងកាលនឹងអ៊ុំចូលចិត្តហ៎?

គ៖ ទិញនំប៉ាវនឹងមកផ្ញើរប៉ាខ្ញុំនឹង(សំលេងរំខាន)!

ខ៖ អឹម!

ក៖ តើបទចំរៀងណាខ្លះដែលអ៊ុំចូលចិត្តស្តាប់?

ខ៖ អឹម! និយាយទៅអ៊ុំចូលចិត្តស្តាប់តែបទណាយ វណ្ណេតនឹង!

ក៖ លោកពូណាយ វណ្ណេត?

ខ៖ នឹងហើយ!

ក៖ សំលេងគាត់ពិរោះណាស់!

ខ៖ នឹងហើយ (សំលេងរញ៉េរញ៉ៃ)!

ក៖ ចឹងពេលដែលអ៊ុំពិបាកចិត្តអ៊ុំចូលចិត្តស្តាប់បទចំរៀងដែរឬទេ?

ខ៖ ចូលចិត្តដែរតែឥលូវមានអីស្តាប់បើគ្មានផងមានអីមើលមានអីស្តាប់!

ក៖ អឹម! ចឹងពេលដែលអ៊ុំពិបាកចិត្តអ៊ុំចូលចិត្តធ្វើអីជាងគេ?(សំលេងកូនក្មេងរញ៉េរញ៉ៃ)!

ខ៖ ពិបាកចិត្តណាស់កូនអ៊ុំពិបាកចិត្តនិយាយមិនចេញទេព្រោះនេះយើងវាស្រួលនេះយើងកំពុងពិបាក!

ក៖ អ៊ឹម!! ដូចថានៅពេលដែលអ៊ុំពិបាកអ៊ុំចូលចិត្តធ្វើអីជាងគេ អង្គុយលេង......? (សំលេងក្មេងស្រែក)!

ខ៖ អង្គុយលេងដេកអង្រឹងចឹងទៅ!

ក៖ហើយអ៊ុំចូលចិត្តមើលមេឃ.....ចាសៗចឹងអ៊ុំមិញទាក់ទងជាមួយនឹងបទចំរៀងអ៊ុំចូលចិត្តបទចំរៀងប៉ុន្តែដោយសារតែឥលូវមានវិទ្យុមានអីដើម្បីស្តាប់ចឹងអ៊ុំធ្វើម៉េចដើម្បីដឹងខ្លួនឯងពេលដែលអ៊ុំពិបាកចិត្តនឹងធ្វើម៉េចដើម្បីកំដរអារម្មណ៍ខ្លួនឯងកុំអ៊ុំពិបាកចិត្តកាត់បន្ថយការពិបាកចិត្តនឹងណាស់អ៊ុំធ្វើម៉េចខ្លះ?

ខ៖ធ្វើម៉េចទេយើងចេះតែឡើងមកលើនិយាយជាមួយគេនឹងទៅគេនាំនិយាយនេះនិយាយនោះទៅយើងកាត់បន្ថយតិចៗចឹងទៅ.....

គ៖ ហើយហ្អែងហើយអាញកោតហ្វែងហើយនេះ (សំលេងរំខាន)!

ខ៖ បើយើងនៅតែក្នុងផ្ទះនឹងតប់ប្រមល់នៅនឹង!

ក៖ចាស
ហើយចឹងអ៊ុំគិតថាអ៊ុំមានពាក្យអីចុងក្រោយដែរទេដើម្បីផ្តែផ្តាំដល់អ្នកដែលបានស្តាប់សំលេងរបស់អ៊ុំណាស់អោយកូនចៅជំនាន់ក្រោយទៀតបានដឹង?

ខ៖ ខ្ញុំមិនដឹងទេកូនមិនដឹងនិយាយថាម៉េចទេ!

ក៖អាចនិយាយថាចេះអ៊ុំចង់មានពាក្យពេជ្យដើម្បីផ្តាំផ្ញើរទៅដល់ក្មេងជំនាន់ក្រោយជាពិសេសអ្នកដែលគាត់កើតជំនាន់ក្រោយមកទៀតដែលគាត់ស្តាប់សំលេងរបស់អ៊ុំនឹងអ៊ុំចង់ផ្តាំផ្ញើរប្រាប់គេអីខ្លះ?

ខ៖ មានអីទេចង់ផ្តាំផ្ញើរអោយកូនខំប្រឹងកុំធ្វើដូចម៉ែចឹងៗណា.....

ក៖ ចាស់!

ខ៖ អោយខំប្រឹងរៀនសូត្រប្រឹងសិក្សាកុំអោយធ្វើដូចម៉ែវេទនាចឹង អស់ហើយអ៊ុំមានតែប៉ុន្នឹង!

កៈ
ចាសអ៊ុំចឹងមានន័យថាអ៊ុំចង់អោយក្មេងជំនាន់ក្រោយគាត់បានខិតខំប្រឹងប្រែងសិក្សារៀនសូត្រ……

ខៈ នឹងហើយ!

កៈ
ហើយគាត់ខិតខំធ្វើការដើម្បីអនាគតពួកគាត់ម្នាក់ៗអោយបានភ្លឺស្វាងអោយមានអនាគតល្អ ហើយនឹងមានសុភមង្គលក្នុងគ្រួសារហើយអាចនឹងរកចំណូលបានដើម្បីចិញ្ចឹមជីវិត…..

ខៈ ចាស់នឹងហើយ!

កៈ ហើយនឹងអោយគ្រួសាររបស់ពួកគាត់រុងរឿងន៍អ៊ុំន៍?

ខៈ នឹងហើយ!

កៈ
ចាសហើយអ៊ុំចឹងដោយសារតែថ្ងៃនេះខ្ញុំមានឪកាសដែលបានសំភាសន៍អ៊ុំផ្ទាល់ជាមួយនឹងប្រវិត្តរបស់អ៊ុំចឹងខ្ញុំនឹងយកសំលេងរបស់អ៊ុំយកទៅដាក់នៅក្នុងវេបសាយខាងសាលា BYU ហាវ៉ៃនៃសហរដ្ឋអាមេរិចនឹងដើម្បីអោយគេធ្វើការរក្សាសំលេងរបស់អ៊ុំទុកដើម្បីអោយក្មេងជំនាន់ក្រោយបានស្តាប់ណាអ៊ុំ?

ខៈ ចាស!

កៈ ចាស ចឹងអរគុណអ៊ុំច្រើនដែលចំណាយពេលវេលាអោយខ្ញុំសំភាសន៍អ៊ុំ(សំលេងរំខាន)!

ខៈ ចាស!

កៈ ចាសអរគុណច្រើនអ៊ុំ!